ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៤៥

59/6

តុលាការកំពូល

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧៨

ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២

សាលដីកា

លេខ: ១១៩

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទីបី ខែឧសភា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ២៥ "ក្រVIញ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៧៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទ: បង្ករបួសស្នាមដោយចេតនា និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងតាមមាត្រា ៣០៧ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស ជាតិខ្មែរ អាយុ៤៨ឆ្នាំ កើតនៅភូមិកញ្ចំ ឃុំកញ្ចំ ស្រុកពារាំង ខេត្តព្រៃវែង សាសនាព្រះពុទ្ធ មុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ៣៦$E_2$ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។



Scanned by CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ១៦ H សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ម៉ោង៥និង៣០នាទីល្ងាច ពេលប្តីឈ្មោះ [redacted] បើកឡានចេញពីក្នុងផ្សារសំពៅមាស ពីកន្លែងលក់ដូរខាងក្នុងមកតាមផ្លូវចំហៀងតូបរបស់ឈ្មោះ [redacted] លុះមកដល់ចំណុចចំហៀងតូបស្រាប់តែឈ្មោះ [redacted] បានទំលាក់ទ្វារតូបមកប៉ះឡានរបស់ឈ្មោះ [redacted] តែពេលនោះដោយឈ្មោះ [redacted] មានធុរៈត្រូវជូនកូនទៅសាលារៀនផង ក៏មិនបានចុះទៅសួរនាំអ្វីដែរ។ លុះព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង៧ និង០០នាទី ពេលប្តីបើកឡានមកដល់ត្រង់ចំហៀងតូបរបស់ឈ្មោះ [redacted] ឈ្មោះ [redacted] ក៏ដើរទៅសួរនាំពីរឿងដែល [redacted] ធ្វើឲ្យប៉ះឡាន ពេលនោះស្រាប់តែឈ្មោះ [redacted] បានជេរប្រមាថ និងចាប់មូលដៃឈ្មោះ [redacted] បណ្តាលឲ្យគ្រិចថ្លោះដៃយ៉ាងធ្ងន់ធ្ងរ ភ្លាមនោះប្តីរបស់ [redacted] ឃើញដូចនោះ ក៏ចេញពីក្នុងឡានទៅចាប់ប្រពន្ធចេញតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា: ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៤៨ឆ្នាំ ទៅជំនុំជំរះ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៩"ន" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច:

១-កែតម្រូវបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ជេរប្រមាថ និងបរិហារកេរ្តិ៍ ប្រព្រឹត្តនៅផ្សារសំពៅមាសសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ តាមមាត្រា៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មក បទជេរប្រមាថជាសាធារណៈ តាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសឈ្មោះ [redacted] ប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៦(ប្រាំមួយ)ខែ តែទោសនេះត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន១.០០០.០០០(មួយលាន)រៀល។

ពីបទ បង្ករបួសដោយចេតនា និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅផ្សារសំពៅមាស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៣០៧ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់អោយឈ្មោះ [redacted] សងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន ៤.០០០.០០០(បួនលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រទាមទារលើសពីនេះបដិសេធចោល។



Scanned by CamScanner

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨១ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ របស់ឈ្មោ[redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ០៩"ខ" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: តម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការតទៅ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៥ក្រVI"ញ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ របស់[redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៩"ខ" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសជាសាធារណៈថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ចំពោះមុខដើមបណ្តឹងកំបាំងមុខជនជាប់ចោទ ទុកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់[redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២៥ក្រVI"ញ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណារបស់ឈ្មោះ[redacted] ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតបរបស់ឈ្មោះ[redacted] ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]ាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាលេខ២៥"ក្រVIញ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

Scanned by CamScanner

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការថា: កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ស្រវឹងស្រា ហើយបើកឡានចូលក្នុងផ្សារសំពៅមាស រេចង្កូតឡានពេញផ្លូវ មកឈប់ជិតតូបរបស់ខ្លួន និងបានជេរមកកាន់ខ្លួនខ្លាំងៗ ក៏បើកទ្វាឡានចេញទៅវិញ។ លុះដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ឈ្មោះ [redacted] និងប្រពន្ធបើកឡានមកឈប់ដល់តូបរបស់ខ្លួនម្តងទៀត ពេលដែលខ្លួនដាក់ទ្វាតូបចុះ រួចក៏បើកឡានចេញទៅវិញដោយមិនបាននិយាយអ្វីសោះ។ មកដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩ អ្នកទាំងពីរបានបើកឡានមកឈប់ដល់តូបរបស់ខ្លួនម្តងទៀត ពេលនោះប្រពន្ធឈ្មោះ [redacted] និយាយថា ពួកឯងបានដាក់ទ្វាពីម្សិលមិញប៉ះលានឆ្កូតថ្នាំ ហើយបានទារលុយពីខ្លួនចំនួន១០$ ថ្លៃជួសជុលឡាន ពេលនោះខ្លួនប្រាប់ថាអត់មានលុយទេ ហើយឈ្មោះ [redacted] និយាយថា ពួងឯងនិយាយស្រួលមិនស្តាប់ ប្រយ័ត្នប្តីខ្ញុំ គាត់ឆេវឆាវណាស់ ពេលឮដូច្នេះប្តីឈ្មោះ [redacted] បានបើកទ្វាឡានចុះមកជេរថា អាឆ្កែ អាចុយម្រាយ គ្រាន់តែលុះ១០ដុល្លា ក៏គ្មានដែរ ពេលនោះខ្លួនមិនតបតអ្វីទេ ពីព្រោះរវល់ធ្វើម្ហូប គ្រាន់តែងើបមុខឡើង មិនទាន់បាននិយាយថាយ៉ាងម៉េចផង ស្រាប់តែឈ្មោះ [redacted] បានដាល់ខ្លួនពីរបីដៃ ធ្វើឱ្យខ្លួនវង្វេងស្មារតីមិនបានតដៃអ្វីទេ។បន្ទាប់មកឈ្មោះ [redacted] បានមកលើកខ្លួនដាក់លើម៉ូតូឌុបយកទៅមន្ទីរពេទ្យតែម្តង។ ដោយខ្លួនមានសាក្សី០២នាក់ ឈ្មោះ [redacted] និង [redacted] ជាអ្នកដឹងឮ ព្រមទាំងមានរូបថតផងដែរ។

-បានស្តាប់សាវតាជាតិ និង ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នាពេលសវនាការថា: ការដែលជនជាប់ចោទនិយាយគឺ មិនពិតទាំងអស់ ហើយគាត់ជេរថា អាចោកពិតជាមានព្រោះខ្លួនមានសាក្សី ឈ្មោះ [redacted] ដែលបានដឹងឮ។

សំណូមពរ: សុំតុលាការកំពូលជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបាន

Scanned by CamScanner

តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលឈ្មោះ [redacted] បានអះអាងថាក្នុងរឿងទំនាស់នេះ ខ្លួនមិនវាយទៅលើជនរងគ្រោះទេ តែជនរងគ្រោះនិងប្តីជនរងគ្រោះទេ ដែលជាអ្នកជេរនិងវាយខ្លួន ដោយខ្លួនសំអាងលើសាក្សីមួយចំនួនមានឈ្មោះ [redacted] រួមនឹងរូបថតផងនោះ តុលាការកំពូលមិនអាចពិចារណាបានឡើយ ពីព្រោះតាមចម្លើយសាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] ឆ្លើយថា ឃើញឈ្មោះ [redacted] ប្រតាយប្រតប់ជាមួយនឹងឈ្មោះ [redacted] ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិនមែនប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ទេ។ ឯចម្លើយឈ្មោះ [redacted] ជនរងគ្រោះម្នាក់ដែរ រួមនឹងសាក្សីឈ្មោះ [redacted] ឆ្លើយប្រហាក់ប្រហែលគ្នាថា នៅថ្ងៃកើតហេតុ គឺមានការប្រតាយប្រតប់គ្នារវាង [redacted] និងជនជាប់ចោទ។ ករណីនេះឃើញថា ភស្តុតាងទាំងនេះមានលក្ខណៈស៊ីសង្វាក់គ្នានិងមានតម្លៃជាភស្តុតាងដាក់បន្ទុកហួសពីវិមតិសង្ស័យ ដែលអាចកំណត់បាននូវអត្ថិភាពនៃបទល្មើសបង្ករបួសដោយចេតនា ដូចការប្រកាសទោសរបស់តុលាការអង្គហេតុហើយ។

-យល់ឃើញថា ការដែលតុលាការអង្គហេតុ សម្រេចប្រកាសទោសលើជនជាប់ចោទពីបទល្មើសជេរប្រមាថជាសាធារណៈតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌនោះ តុលាការអង្គហេតុមិនទាន់បានបង្ហាញអំពីសំអាងហេតុដាក់បន្ទុកណាមួយ ទាក់ទិននឹងសកម្មភាពជេរប្រមាថទេ ក្រៅតែពីសំអាងតែទៅលើចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលអះអាងនាពេលទំនាស់នោះ ជនជាប់ចោទបានជេរខ្លួនដោយប្រើពាក្យ "ចោក" តែប៉ុណ្ណោះ។ ចម្លើយនេះមិនអាចចាត់ទុកជាភស្តុតាងដាក់បន្ទុកបានឡើយ។ ឯការដែលតុលាការអង្គហេតុសំអាងហេតុសម្រេចបង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តចំនួន៤លានរៀលឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីនោះ ក៏ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយដែរ ព្រោះថាមិនទាន់បង្ហាញអំពីសំអាងហេតុនៃទំហំខូចខាតគតិវិតណានោះទេ។ ករណីនេះបង្ហាញថាការធ្វើសំអាងហេតុមិនគ្រប់គ្រាន់ ដែលចាត់ទុកថាមិនមានសំអាងហេតុ។ ដូច្នេះតាមស្មារតីមាត្រា៤១៩ ចំណុចទី៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ម្ចាស់បណ្តឹងសាទុក្ខមានមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួនហើយ។

-យល់ឃើញថា ការដែលតំណាងមហាអយ្យការអមតុលាការកំពូល ប្តឹងសុំឲ្យតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែលនោះ តុលាការកំពូលបានពិចារណាដូចខាងលើហើយ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៥ ក្រVIញ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រឹមត្រូវហើយ លើកលែងតែចំណុចស្តីពីអត្ថិភាពនៃបទជេរប្រមាថ និងសំណងរដ្ឋប្បវេណី ខុសនឹងគតិច្បាប់។

Scanned by CamScanner

៩០

59/1

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១- ទទួលផ្នែកខ្លះ និងបដិសេធផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៥ "ក្រVIញ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុចស្តីពីការផ្តន្ទាទោសក្នុងបទជេរប្រមាថ និងសំណងរដ្ឋប្បវេណី ត្រូវបដិសេធចោល។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៧៨ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះសាជាថ្មីអំពីចំណុចខាងលើនេះ។

៤- សាលដីកានេះជំនុំជំរះនាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៣

ប្រធានតុលាការកំពូល

[redacted]